# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៧ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពី

### ការទទួលស្គាល់វិទ្យាស្ថានអប់រំកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក. ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ១៧៩៦ អយក.ឧស. ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៨

# ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានអប់រំកម្ពុជា** ( **Institute of Cambodian Education** ) សរសេរកាត់ជាភាសាខ្មែរ " **វ.អ.ក** " និងសរសេរកាត់ជាភាសាអង់គ្លេស " **I.C.E** " ។

**មាត្រា ២ :** វិទ្យាស្ថានអប់រំកម្ពុជា មានទីតាំងស្ថិតនៅ អគារលេខ ៥ ផ្លូវលេខ ២០០ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** វិទ្យាស្ថានអប់រំកម្ពុជា ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ។ វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីចាប់ដំណើរការបាន ៦ ( ប្រាំមួយ ) ខែ ។

**មាត្រា ៤ :** វិទ្យាស្ថានអប់រំកម្ពុជាមាន ពីរមហាវិទ្យាល័យ :

-មហាវិទ្យាល័យ ភាសាបរទេស

-មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ កម្រិតឬថ្នាក់ប្រភេទបណ្តុះបណ្តាលដទៃទៀត ពង្រីកឬប្តូរទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** វិទ្យាស្ថានអប់រំកម្ពុជា មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃវិទ្យាស្ថានអប់រំកម្ពុជា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានអប់រំកម្ពុជា ។

**មាត្រា ៦ :** នាយកវិទ្យាស្ថាន មានភារកិច្ច :

-ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថាននេះ និងធានាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ។

-គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ។

-រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ស្របតាមការណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

-គោរពតាមកិច្ចសន្យាដែលវិទ្យាស្ថានអប់រំកម្ពុជា បានសន្យាចំពោះក្រសួងអប់រំ យុវជន និងកីឡា ។

-ធ្វើរបាយការណ៍ អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

**មាត្រា ៧ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានអប់រំកម្ពុជា និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា ។ សញ្ញាបត្រនេះ

ផ្តល់ឱ្យដោយវិទ្យាស្ថានអប់រំកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថានអប់រំកម្ពុជា បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិទ្យាស្ថានអប់រំកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ